## ៨-២-២ បុណ្យវិសាខបូជា

បុណ្យវិសាខបូជា គេធ្វើនៅ ថ្ងៃពេញបូណ៌មី ខែវិសាខ ដើម្បីរំលឹក **ថ្ងៃប្រសូត ថ្ងៃត្រាស់ដឹង** និង **ថ្ងៃបរិនិព្វាន** នៃ ព្រះសម្មាសម្ពុទ្ធ ។

ថ្ងៃប្រសូត :

ព្រះអង្គប្រសូត ថ្ងៃសុក្រ ពេញបូណ៌មី ខែវិសាខ ឆ្នាំច មុនព.ស. ៨០ ឆ្នាំ ។

ថ្ងៃត្រាស់ដឹង :

ព្រះអង្គត្រាស់ដឹង ថ្ងៃពុធពេញបូណ៌មី ខែវិសាខ ឆ្នាំរកា មុន ព.ស. ៤៥ ឆ្នាំ ។

ថ្ងៃបរិនិព្វាន :

ព្រះអង្គចូលបរិនិព្វាន ថ្ងៃអង្គារពេញបូណ៌មី ខែ វិសាខ ឆ្នាំម្សាញ់ ដែលទុកជាថ្ងៃចាប់ផ្ដើមនៃពុទ្ធសករាជ ហើយគេកំណត់យក ថ្ងៃ១រោចខែវិសាខ ឆ្នាំម្សាញ់នោះជាថ្ងៃទី ១ នៃ ពុទ្ធសករាជ ។

ប្រសូតក៏ថ្ងៃពេញបូណ៌មី ត្រាស់ដឹងក៏ថ្ងៃពេញបូណ៌មី បរិនិព្វានក៏ថ្ងៃពេញបូណ៌មី ដូចនេះ ថ្ងៃពេញបូណ៌មី មានន័យ សំខាន់ណាស់ ចាស់ៗ លោក តំណាលថា : "ធ្វើបុណ្យ១ដង បានផលដល់ទៅ ៣ដង" ។ បណ្ដា ថ្ងៃទាំង៣ ថ្ងៃត្រាស់ដឹងសំខាន់ណាស់ ព្រោះព្រះពុទ្ធបាននាំមកនូវពន្លឺដ៏មហាស្ចារ្យ ដល់សត្វលោក ដែលមិនអាចរកសាស្ដាណា មកប្រៀបផ្ទឹមបាន។ហេតុនេះហើយបានជា នៅថ្ងៃដ៏សំខាន់នេះ ពីដើមមកគេធ្វើបុណ្យ គគ្រឹក គគ្រេង មិនដូចឥឡូវនេះ ដែលដូចជាសោះកក្រោះពេកណាស់។ យើងគួរតែប្រដាប់គ្រប់ផ្ទះ សម្បែងដោយទង់ជាតិ ទង់សាសនា រៀបក្ដីផ្កា ប្រទីបធូបលាបូជាព្រះរតនត្រ័យ ឲ្យបានល្អ ។ ចំណែកនៅវត្តអារាម គួរតែនាំគ្នា ធ្វើបុណ្យវិសាខ

បូជាឲ្យកើតសទ្ធាជ្រះថ្លា មានបញ្ញាភ្លឺស្វាងច្រើនឡើង លើសថ្ងៃបុណ្យឯទៀតៗ ដើម្បីបូជាចំពោះព្រះពុទ្ធបរមគ្រូយើង គួរយើងប្រមូលទ្រព្យរួមគ្នា សាងសាលារៀន ១ខ្នង ឬ អ្វីមួយជាដើម ទុកជាទីរលឹកនៅថ្ងៃបុណ្យវិសាខបូជា។

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ " ← " ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។